# ព្រះរាជាណាចក្រកម្ពុជា

## ជាត សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈនៃការយោគយល់

## រវាង

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## និង

## អង្គការវីនរ៉ក់អន្តរជាតិ

## ស្តីពី

## គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា

# បុព្វកថា

**ដោយហេតុថា៖** អំពើជួញដូរមនុស្សនៅតែជាបញ្ហាប្រឈម ដែលបន្តផ្តល់ផលអវិជ្ជមានប៉ះពាល់ដល់សុខុមាលភាព សិទ្ធិ សេរីភាព និងសេចក្តីថ្លៃថ្នូររបស់ប្រជាជនកម្ពុជា។

**ដោយហេតុថា៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) គឺជាយន្តការជាតិពហុវិស័យរបស់ព្រះរាជាណាចក្រកម្ពុជា ដែលទទួលខុសត្រូវក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសម្តែង នូវបំណងប្រាថ្នា ក្នុងការរួមសហការជាមួយអង្គការវីនរ៉ក់អន្តរជាតិ ដើម្បីចូលរួមលុបបំបាត់ឫសគល់នៃអំពើជួញដូរមនុស្ស តស៊ូមតិ និងការពារប្រជាជនងាយរងគ្រោះពីការជួញដូរមនុស្ស និងការរំលោភបំពានផ្សេងៗ បង្ការទប់ស្កាត់កុំឱ្យមានការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ព្រមទាំងលើកកម្ពស់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចគាំពារជនរងគ្រោះ និងក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាព។

**ដោយយល់ថា៖** អង្គការវីនរ៉ក់អន្តរជាតិចាប់ផ្តើមគម្រោងមួយ មានឈ្មោះថា "គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា" ដែលហៅកាត់ថា (CTIP) ដើម្បីពង្រឹងការអនុវត្តយុទ្ធសាស្ត្រទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ពង្រឹង និងអនុវត្តប្រព័ន្ធការពារជនរងគ្រោះ បង្កើនការទទួលខុសត្រូវចំពោះមុខច្បាប់ដល់ជនល្មើស ព្រមទាំងបង្កើត និងកែលម្អភាពជាដៃគូ ដើម្បីឈានទៅលុបបំបាត់អំពើជួញដូរមនុស្ស។

**ដោយហេតុថា៖** គ.ជ.ប.ជ និង អង្គការវីនរ៉ក់អន្តរជាតិ ចាំបាច់ត្រូវសហការដើម្បីឆ្លើយតបចំពោះអនុសាសន៍សម្រាប់កម្ពុជា ដែលមានចែងនៅក្នុងរបាយការណ៍ស្តីពីអំពើជួញដូរមនុស្សរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក និងសំដៅពង្រឹងប្រសិទ្ធភាព វិធានការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។

## ប្រការ១
## គោលបំណង

អនុស្សរណៈនៃការយោគយល់នេះមានគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការរវាង គ.ជ.ប.ជ និងអង្គការវីនរ៉ក់អន្តរជាតិ តាមរយៈ CTIP ដើម្បីរួមចំណែក លើកកម្ពស់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបង្កើនប្រសិទ្ធភាពវិធានការប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ។

## ប្រការ ២
## ការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**ដើម្បីឱ្យការអនុវត្តអនុស្សរណៈនេះទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានព្រមព្រៀងដូចខាងក្រោម ៖**

- អនុញ្ញាតឱ្យអង្គការវីនរ៉ក់អន្តរជាតិ បំពេញការងាររបស់ខ្លួន ដោយអនុលោមតាមច្បាប់ និងបទដ្ឋានគតិយុត្ត នៃព្រះរាជាណាចក្រកម្ពុជា។
- សហការជាមួយអង្គការវីនរ៉ក់អន្តរជាតិ ដើម្បីពិភាក្សាក្នុងការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តជាកិច្ចសហការក្នុងអាណត្តិនៃគម្រោងឱ្យមានសង្គតភាពរវាងគម្រោង CTIP និងផែនការយុទ្ធសាស្ត្រជាតិ គ.ជ.ប.ជ ។
- សម្របសម្រួល និងអនុញ្ញាតឱ្យអង្គការវីនរ៉ក់អន្តរជាតិ ចូលរួមធ្វើការងារជិតស្និទ្ធជាមួយក្រុមការងារអន្តរក្រសួង និងស្ថាប័នជំនាញពាក់ព័ន្ធ ដែលជាសមាជិករបស់ គ.ជ.ប.ជ និងចូលរួមធ្វើការងារជាមួយ អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ទៅតាមផែនការដែលបានកំណត់ដោយឯកភាពគ្នា ដើម្បីសម្រេចគោលបំណងដូចមានចែងក្នុងប្រការ១។
- សម្របសម្រួល និងអនុញ្ញាតឱ្យអង្គការវីនរ៉ក់អន្តរជាតិ ចូលរួមមតិ ក្នុងការរៀបចំ និងកែលម្អគោលនយោបាយ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- សម្របសម្រួល និងអនុញ្ញាតឱ្យអង្គការវីនរ៉ក់អន្តរជាតិ បានចូលរួម ក្នុងការសិក្សា ស្រាវជ្រាវស្ទង់មតិ ប្រមូលចងក្រង បទពិសោធន៍ គំរូអនុវត្តល្អ និងបញ្ហាប្រឈមដែលទទួលបាននិងជួបប្រទះក្នុងការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងដើម្បីចែករំលែកគំហើញទាំងនោះ ដល់ភាគីពាក់ព័ន្ធទាំងអស់ក្នុងកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា។
- ដឹកនាំសម្របសម្រួលគណៈកម្មាធិការរាជធានី-ខេត្ត ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ/គ.ខ.ប.ជ) នៅតាមតំបន់គោលដៅរបស់ CTIP (ភ្នំពេញ កោះកុង ព្រះសីហនុ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ចាម និងព្រៃវែង) ចូលរួមសហការក្នុងសកម្មភាពគម្រោង និងរាយការណ៍សមិទ្ធផលការងារដែលសម្រេចបាន ទៅ គ.ជ.ប.ជ។
- ចែករំលែកបទពិសោធន៍នានា និងសមិទ្ធផលការងារដែលទទួលបាន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពការងាររបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ប្រការ៣

## ការទទួលខុសត្រូវរបស់អង្គការ វីនរ៉ក់អន្តរជាតិ

**អង្គការវីនរ៉ក់អន្តរជាតិទទួលខុសត្រូវដូចខាងក្រោម៖**

- ត្រូវគ្រប់គ្រងមូលនិធិដែលផ្តល់ដោយទីភ្នាក់ងារសហរដ្ឋអាម៉េរិក សម្រាប់ការអភិវឌ្ឍអន្តរជាតិដើម្បីបម្រើដល់ការអនុវត្តសកម្មភាពរបស់គម្រោងឱ្យមានប្រសិទ្ធភាព ចំគោលដៅ និងគោរពឱ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងបទប្បញ្ញត្តិរបស់ព្រះរាជាណាចក្រកម្ពុជា និងមិនអនុញ្ញាតឱ្យភ្នាក់ងាររបស់ខ្លួនចូលរួមរាល់សកម្មភាពណាមួយដែលអាចបង្កអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីរបស់ប្រជាជនកម្ពុជា។

- តំបន់គោលដៅដែលត្រូវអនុវត្តសកម្មភាពរបស់គម្រោង CTIP គឺៈ រាជធានីភ្នំពេញ ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តកំពង់ចាម និងខេត្តព្រៃវែង។
- ប្រតិបត្តិរាល់សកម្មភាពដែលបានព្រមព្រៀងគ្នា ក្នុងលក្ខណៈមនុស្សធម៌ ដើម្បីពង្រឹងការអនុវត្តយុទ្ធសាស្ត្រទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅបង្ការទប់ស្កាត់អំពើជួញដូរមនុស្សពង្រឹង និងអនុវត្តប្រព័ន្ធការពារជនរងគ្រោះ បង្កើនការទទួលខុសត្រូវចំពោះមុខច្បាប់ដល់ជនល្មើស ព្រមទាំងបង្កើត និងកែលម្អភាពជាដៃគូ ដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស ដោយអនុលោមតាម ផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគោលនយោបាយពាក់ព័ន្ធនឹងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិ របស់ព្រះរាជាណាចក្រកម្ពុជា។
- ចូលរួមផ្តល់មតិក្នុងការកែលម្អ ឬរៀបចំគោលនយោបាយ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។
- ចូលរួមសិក្សាស្រាវជ្រាវ ស្ទង់មតិយោបល់ និងប្រមូលចងក្រង បទពិសោធន៍ គំរូអនុវត្តល្អ និងបញ្ហាប្រឈមដែលទទួលបាន និងចែករំលែកគំហើញទាំងនោះដល់ភាគីពាក់ព័ន្ធ។
- សហការជាមួយគណៈកម្មាធិការរាជធានី-ខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ/គ.ខ.ប.ជ) នៅតាមតំបន់គោលដៅរបស់ CTIP (ភ្នំពេញ កោះកុង ព្រះសីហនុ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ចាម និងព្រៃវែង) ក្នុងការអនុវត្តសកម្មភាពគម្រោងដែលបានឯកភាពគ្នា និងរាយការណ៍សមិទ្ធផលការងារដែលសម្រេចបានប្រចាំឆ្នាំ ទៅ គ.ជ.ប.ជ។
- ចូលរួមសកម្មភាពចាំបាច់នានាដែលរៀបចំដោយ គ.ជ.ប.ជ ក្នុងគោលដៅប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ចូលរួមកិច្ចប្រជុំទៀងទាត់របស់លេខាធិការដ្ឋាន នៃរាជធានី និងខេត្តគោលដៅ និងកិច្ចប្រជុំរៀបចំដោយ គ.ជ.ប.ជ ដើម្បីចែករំលែកព័ត៌មាន ឬទិន្នន័យស្តីពីវឌ្ឍនភាព បទពិសោធន៍នានា និងសមិទ្ធផលការងារដែលទទួលបាន។
- ចូលរួមតែសកម្មភាពការពារសិទ្ធិ និងផលប្រយោជន៍របស់ពលករទេសន្តរប្រវេសន៍ និងសកម្មភាពមនុស្សធម៌ដែលទទួលបានការអនុញ្ញាតពី គ.ជ.ប.ជ ដើម្បីសុខុមាលភាពសង្គម និងប្រយោជន៍សាធារណៈ។
- ជៀសវាងដាច់ខាតការចូលរួមពាក់ព័ន្ធគ្រប់សកម្មភាពនយោបាយ។
- ជូនដំណឹងជាលាយលក្ខណ៍អក្សរដល់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្តីពីការផ្លាស់ប្តូរណាមួយដូចជា អាសយដ្ឋានការិយាល័យគម្រោង អ្នកតំណាង ឬប្រធានគម្រោង។
- សេចក្តីសង្ខេបអំពីគម្រោងមានចែងលម្អិតក្នុងឧបសម្ពន (១)។

# ប្រការ៤

## ការដោះស្រាយវិវាទ

រាល់វិវាទដែលអាចកើតឡើងពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តអនុស្សរណៈយោគយល់នេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការវីនរ៉ក់អន្តរជាតិ ត្រូវដោះស្រាយតាមរយៈការចរចាដោយសន្តិវិធីរវាងភាគីទាំងពីរ ។

# ប្រការ ៥

## អវសានប្បញ្ញត្តិ

អនុស្សរណៈយោគយល់នេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា និងមានសុពលភាពរយៈពេល ៣(បី)ឆ្នាំ ហើយអាចបន្តសុពលភាពបានទៀតដោយមានការយល់ព្រមពីភាគីទាំងពីរ។

ភាគីម្ខាងអាចជូនដំណឹងទៅភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ ក្នុងពេលណាក៏បាន ប្រសិនបើខ្លួនមានបំណងបញ្ចប់អនុស្សរណៈនេះ ។ អនុស្សរណៈយោគយល់ នឹងត្រូវបញ្ចប់ក្នុងរយៈពេល ៦០ (ហុកសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង។

អនុស្សរណៈយោគយល់នេះ ធ្វើឡើងជាពីរច្បាប់ដើម ជាភាសាខ្មែរ និងភាសាអង់គ្លេស ដែលអត្ថបទទាំងពីរភាសាមានតម្លៃស្មើគ្នា។ ក្នុងករណីមិនមានការឯកភាពគ្នាលើការបកស្រាយអត្ថបទទាំងនេះ អត្ថបទជាភាសាខ្មែរត្រូវយកជាគោល ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...២៨....ខែ...កុម្ភៈ.....ឆ្នាំ ២០២២

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**
**អនុប្រធានអចិន្ត្រៃយ៍**

**ជូ ប៊ុនអេង**

**តំណាងអង្គការ**
**វីនរ៉ក់អន្តរជាតិ**
**ប្រធានគម្រោង CTIP**

**ម៉ាក ថេយល័រ**

# ឧបសម្ព័ន្ធ

## សង្ខេបអំពីគម្រោង

- ឈ្មោះស្ថាប័ន ៖ អង្គការវីនរ៉ក់អន្តរជាតិ (Winrock International)
- ប្រភេទស្ថាប័ន ៖ អង្គការអន្តរជាតិ
- បានចុះបញ្ជីនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៖ នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០
- អាសយដ្ឋានការិយាល័យគម្រោង៖ បន្ទប់ ៥A-៥C អគារ១៨ ផ្លូវ៥៧៨ ខណ្ឌទួលគោក រាជធានីភ្នំពេញ
- ទូរស័ព្ទ ៖ (+៨៥៥) ៧៧ ៨៨៨ ០៣៨ / ១៥ ៨៨៨ ០៣៨
- អ៊ីម៉ែល ៖ Mark.Taylor@winrock.org
- ឈ្មោះគម្រោង ៖ គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា
- ថវិកាអនុវត្តគម្រោង ៖ USD ៨,៥០០,000.00 (ប្រាំបីលាន ប្រាំរយពាន់ដុល្លារសហរដ្ឋអាម៉េរិកគត់)
- កាលបរិច្ឆេទចាប់ផ្តើម ៖ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១
- កាលបរិច្ឆេទបញ្ចប់ ៖ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៦
- ទីកន្លែងអនុវត្តគម្រោង ៖ រាជធានីភ្នំពេញ ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តកំពង់ចាម និងខេត្តព្រៃវែង
- ចំនួនបុគ្គលិកបរទេស ៖ ១ នាក់
- ចំនួនបុគ្គលិកខ្មែរ ៖ ១៣ នាក់ ។

# KINGDOM OF CAMBODIA

## NATION RELIGION KING

## MEMORANDUM OF UNDERSTANDING

## BETWEEN

## NATIONAL COMMITTEE FOR COUNTER TRAFFICKING

## AND

## WINROCK INTERNATIONAL

## ON

## CAMBODIA COUNTER TRAFFICKING IN PERSONS

## PREAMBLE

**WHEREAS** Trafficking in persons remains a challenge that continues to negatively impact well-being, safety, rights, and dignity of the Cambodian people.

**WHEREAS** The National Committee for Counter Trafficking (hereinafter referred to as NCCT), the national multi-sectoral mechanism of Cambodia in charge of counter-trafficking efforts, has expressed its desire to collaborate with Winrock International to address the root causes of trafficking, advocate and protect vulnerable populations from trafficking and abuse, prevent at-risk populations from risky migration, and assist the Royal Government of Cambodia (RGC) in reforms needed to effectively combat trafficking and support victims.

**WHEREAS** Winrock International embarks upon a project entitled 'Cambodia Counter Trafficking in Person', hereinafter referred to as CTIP, to enhance national and local strategies implementation to prevent trafficking in persons; strengthen protection system and implementation for victims; increase accountability for perpetrators; and to establish and improve partnership to address trafficking in persons.

**WHEREAS** NCCT and Winrock International need to co-operate in addressing the recommendations for Cambodia stated in the United States Department of State's Trafficking in Persons report and working towards improving the effectiveness of counter-trafficking measures.

## ARTICLE 1
## Objective

This Memorandum of Understanding (MoU) aims to increase cooperation between NCCT and Winrock International through CTIP to contribute to enhancing counter-trafficking efforts and improving the effectiveness of counter-trafficking measures in Cambodia.

## ARTICLE 2
## Responsibilities of the National Committee for Counter Trafficking

In order for the implementation of this MoU to be successful and highly effective, the National Committee for Counter Trafficking (NCCT) has agreed as follows:

- Allow Winrock International to carry out its activities in accordance with the laws and regulations of Cambodia.
- Cooperate with Winrock International to discuss the development of a collaborative action plan so that the implementation of CTIP activities is in consistent with the national strategic plan of the NCCT.

- Coordinate and allow Winrock International to engage with all the ministries, institutions and specialized agencies that are members of the NCCT as well as the NCCT General Secretariat, according to the agreed plan, in order to achieve the objective stated under Article 1 of this MoU.
- Coordinate and allow Winrock International to engage in the development and improvement of policies, laws and regulations that contribute to improving Cambodia's efforts to combat trafficking in persons.
- Coordinate and allow Winrock International to engage in research; study; survey to collect lessons learned, best practices and challenges on Cambodia's efforts to combat trafficking in persons; and to disseminate the findings thereof to counter-trafficking stakeholders in Cambodia.
- Coordinate with Municipal and Provincial Committees for Counter Trafficking (M/PCCTs) in the target areas (Phnom Penh, Koh Kong, Preah Sihanouk, Battambang, Banteay Meanchey, Siem Reap, Kampong Cham, and Prey Veng) to engage in the activities of Winrock International through CTIP and to report the achieved results to the NCCT.
- Share experiences and the achievements to counter-trafficking stakeholders at national and sub-national levels for the purpose of improving the effectiveness of counter-trafficking efforts.

## ARTICLE 3

### Responsibilities of Winrock International

Winrock International has the responsibilities as follow:

- Winrock International shall manage the fund supported by the United States Agency for International Development for the purpose of effective implementation of all the activities under CTIP and shall comply with Laws and Regulations of Cambodia, and Winrock shall not allow its staff to participate in any activity that could be harmful to national security, national unity, culture and tradition of Cambodia.
- The target areas for CTIP activities implementation are Phnom Penh, Koh Kong, Preah Sihanouk, Battambang, Banteay Meanchey, Siem Reap, Kampong Cham, and Prey Veng.
- Winrock International shall implement all agreed activities in a humanitarian manner to enhance national and local strategies implementation to prevent trafficking in persons; strengthen protection system and implementation for victims; increase accountability for perpetrators; and to establish and improve partnership to address trafficking in persons in accordance with National Strategic Plan for Counter Trafficking in Persons and its policies upholding the principles of cooperation according to Cambodia's laws.

- Shall engage in the development and improvement of policies, laws and regulations that contribute to improving Cambodia's efforts to combat trafficking in persons.
- Shall engage in research; study; survey to collect lessons learned, best practices and challenges on Cambodia's efforts to combat trafficking in persons; and disseminate the findings thereof to counter-trafficking stakeholders in Cambodia.
- Shall engage with Municipal and Provincial Committees for Counter Trafficking (M/PCCTs) in the target areas (Phnom Penh, Koh Kong, Preah Sihanouk, Battambang, Banteay Meanchey, Siem Reap, Kampong Cham, and Prey Veng) in the implementation of agreed activities and in reporting the achieved results to the NCCT on an annual basis.
- Engage in other necessary activities and events organized by the NCCT for counter-trafficking purpose.
- Attend regular meetings organized by the municipal and provincial secretariats in target areas and meetings organized by the NCCT to share information or data on progress, experience and achievements made.
- Shall only engage in activities for the purpose of protection of migrant workers' rights and benefits and other humanitarian activities as allowed by the NCCT for the sake of social wellbeing and public benefits.
- Shall not engage in any political activities.
- Shall notify the NCCT in written format about any changes regarding CTIP office address or CTIP Chief of Party.
- Project summary is mentioned in Annex.

## ARTICLE 4
## Dispute Resolution

All differences arising between NCCT and Winrock International related to the interpretation or implementation of the MoU shall be resolved amicably through peaceful negotiation between both parties.

## ARTICLE 5
## Final Provision

This Memorandum of Understanding shall enter into effect on the date of signing by both parties and shall remain effective for three (3) years and can be extended upon agreement between both parties.

This Memorandum of Understanding can be terminated by either party in form of written notice. The termination shall take effect sixty (60) days following the date of written notice to the other party.

This Memorandum of Understanding is done in duplicate in Khmer and English. All texts shall be equally authentic. In case of any divergence of interpretation, the Khmer text shall prevail.

Phnom Penh, 28 February 2022

| National Committee for Counter Trafficking | Winrock International |
| --- | --- |
| Permanent Vice-Chairperson | CTIP Chief of Party |
| CHOU BUN ENG | MARK TAYLOR |

# ANNEX

## PROJECT SUMMARY

- Organization Name : Winrock International
- Organization Type : Foreign Non-Governmental Organization
- Registered at Ministry of Foreign Affair and International Cooperation on August 31, 2020
- Address of CTIP Office : Room 5A-5C, Building 18, Street 578, Khan Toul Kork, Phnom Penh, Cambodia
- Tel : (+855) 77 888 038, (+855) 15 888 038
- Email : Mark.Taylor@winrock.org
- Project Name : Cambodia Counter Trafficking in Persons
- Project Budget : $8,500,000.00
- Project start date : March 22, 2021
- Project end date : March 21, 2026
- Project target areas : Phnom Penh, Koh Kong, Preah Sihanouk, Battambang, Banteay Meanchey, Siem Reap, Kampong Cham, and Prey Veng
- Foreigner staff : 1
- Cambodian staff : 13